# ជំពូកទី១

# សេចក្ដីផ្ដើម

Draft

# ជំពូកទី ១

# សេចក្តីផ្តើម

## ១.១ លក្ខណៈទូទៅនៃគំរោង

ព្រះរាជាណាចក្រកម្ពុជា ក្នុងពេលបច្ចុប្បន្នកំពុងតែមានសន្ទុះអភិវឌ្ឍន៍ និងរីកលូតលាស់លើគ្រប់ហេដ្ឋារចនាសម្ព័ន្ធ និងលើគ្រប់វិស័យយ៉ាងឆាប់រហ័ស បើទោះបីជាប្រទេសកម្ពុជា ទើបតែបានរួចចាកផុតពីសង្គ្រាមដ៏រ៉ាំរ៉ៃជាង ២ ទសវត្សកន្លងមកក៏ដោយ នេះគឺអាស្រ័យដោយសារកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងពុះពារគ្រប់ឧបសគ្គ ពីសំណាក់រាជរដ្ឋាភិបាល និងការចូលរួមពីគ្រប់ស្ថាប័នក្រោមឱវាទទាំងអស់។

វិស័យដែលមានសក្តានុពលសំខាន់បំផុតនោះគឺ វិស័យកសិកម្ម និងកសិ-ឧស្សាកម្ម ដែលបានដើរតួនាទីយ៉ាងសំខាន់រួមចំណែកជួយស្តារ កសាង និងអភិវឌ្ឍសេដ្ឋកិច្ចជាតិអោយរីកចំរើន និងបូករួមទាំងការចូលវិនិយោគនៅលើគ្រប់ផ្នែកទាំងអស់ គឺទាំងការវិនិយោគផលិតទំនិញនាំចេញ ការផលិតថាមពល ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគផ្នែកទេសចរណ៍ ក៏ដូចជាវិស័យសំខាន់ៗដ៏ទៃទៀត ដែលបានជួយជំរុញការអភិវឌ្ឍន៍ និងជំរុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា អោយមានសន្ទុះលឿនថែមមួយកំរិតទៀត។

ស្របតាមគោលនបោយកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី ២ បានផ្តល់អាទិភាពខ្ពស់ដល់ការលើកស្ទួយវិស័យកសិកម្ម ក្នុងចំណោមវិស័យសំខាន់ៗដ៏ទៃទៀត ក៏ដូចជាច្បាប់វិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់ការអនុគ្រោះ និងលើកទឹកចិត្តយ៉ាងច្រើនសំរាប់វិស័យនេះ ក៏ដូចជាវិស័យដ៏ទៃៗទៀតផងដែរ ដើម្បីទាក់ទាញវិនិយោគិនក្នុង និងក្រៅប្រទេសអោយចូលមកធ្វើការដាក់ទុនវិនិយោគឱ្យកាន់តែច្រើន ជាពិសេសគោលនយោបាយផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់អ្នកវិនិយោគ គឺដើម្បីវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម ដែលមានដូចជា : ដើមដូងប្រេង ដើមអាកាស្យា ដើមល្ហុងខ្វង និងដើមកៅស៊ូជាដើម។ អាស្រ័យដោយប្រទេសកម្ពុជាមានលក្ខណៈអំណោយផលទៅនឹងអាកាសធាតុ ភូមិសាស្រ្ត និងមានទីតាំងស្ថិតនៅតំបន់ត្រូពិច ព្រមទាំងមានធនធានទំនេរដែលសំបូរជីវជាតិស្រាប់ ដែលមានលក្ខណៈអំណោយផលចំពោះការដាំដំណាំច្រើនមុខ ជាពិសេសដំណាំកសិ-ឧស្សាហកម្មនេះតែម្តង។

តាមរយៈការជំរុញលើកទឹកចិត្តខ្ពស់បែបនេះ និងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យកសិកម្ម។ ខេត្តមណ្ឌលគិរីក៏មានផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្ត សំដៅធ្វើឱ្យមានកំណើនប្រាក់ចំណូលដល់ប្រជាកសិករ ក៏ដូចជាបងប្អូនជនជាតិដើមភាគតិចតាមរយៈការបង្កើនកាលានុវត្តភាពការងារការវិនិយោគឯកជន សាធារណៈ និងការពង្រឹងផលិតកម្ម សេវាកម្ម ប្រកបដោយចីរភាព។ គោលដៅចំបងនេះ គឺផ្តោតជា

សំខាន់ទៅលើការអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្ម ដោយត្រូវបង្កើនទិន្នផលឱ្យបានខ្ពស់ ស្តារ និងធ្វើការពង្រីកប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាការស្រោចស្រព និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។

ដោយផ្អែកលើលក្ខណៈអំណោយផលនានា ឱកាស និងការឆ្លើយតបចំពោះតំរូវការក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ក៏ដូចជាការអភិវឌ្ឍន៍ក្នុងតំបន់នៃខេត្តមណ្ឌលគីរី ជាពិសេសដើម្បីចូលរួមចំណែកជួយរាជរដ្ឋាភិបាលសំរេចបាននូវទិសដៅដែលបានដាក់ចេញ ក្រុមហ៊ុន **សេដ្ឋីកុលា (SETHIKULA Co., Ltd.)** បានពិនិត្យឃើញថាការវិនិយោគទុនទៅលើគំរោង **ដាំដំណាំកសិ-ឧស្សាហកម្មដំណាំកៅស៊ូ** ដែលជាការវិនិយោគមួយសមស្របបំផុតនៅលើទឹកដីនៃ ឃុំប៊ូស្រា ស្រុកពេជ្រាដា និងឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ព្រោះការវិនិយោគនេះដើរស្របគ្នាជាមួយនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តផងដែរ។ ម្យ៉ាងវិញទៀតទីតាំងភូមិសាស្ត្រ ស្ថានភាពដីនៅទីនោះអំណោយផល និងអនុគ្រោះច្រើនដល់ការដាំដំណាំកសិ-ឧស្សាហកម្ម ហើយតំរូវការនៃដំណាំនេះបច្ចុប្បន្នកំពុងតែមានតំរូវការកើនឡើងជាលំដាប់។

ហេតុនេះក្រោយពីបានសិក្សាយ៉ាងល្អិតល្អន់ ព្រមទាំងការផ្តល់យោបល់ដោយអ្នកជំនាញបច្ចេកទេសជាច្រើនរួចមក ក្រុមហ៊ុនបានសំរេចវិនិយោគលើការដាំដើមកៅស៊ូ សំរាប់បំពេញសេចក្តីត្រូវការក្នុងប្រទេស ក៏ដូចជាការនាំចេញ។

ថ្វីត្បិតតែការវិនិយោគនេះនឹងអាចផ្តល់នូវគុណប្រយោជន៍ចំពោះការលើកកំពស់ ការអភិវឌ្ឍន៍សកម្មភាពសេដ្ឋកិច្ចខេត្តមណ្ឌលគីរី និងសកម្មភាពសេដ្ឋកិច្ចជាតិក្តី ក៏ផលអវិជ្ជមានជាច្រើននឹងអាចកើតមានឡើងស្របគ្នាផងដែរ ដែលឥទ្ធិពលជាអវិជ្ជមានទាំងនោះរួមមាន : ការបាត់បង់ធនធានព្រៃឈើធម្មជាតិនៅក្នុងតំបន់បន្ទាប់ពីគំរោងធ្វើការឈូសឆាយ ការបាត់បង់ និងខូចខាតគុណភាពដី និងការបំពុលទឹកជាដើម ដែលតំរូវឱ្យក្រុមហ៊ុនត្រូវធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ដើម្បីស្វែងយល់អំពីហេតុប៉ះពាល់នានា ព្រមជាមួយនឹងការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់។

## ១.២ គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សាគំរោងវិនិយោគដីសម្បទានរបស់ក្រុមហ៊ុន **សេដ្ឋីកុលា (SETHIKULA Co., Ltd.)** នេះគឺចង់បង្ហាញពីគោលនយោបាយនៃការអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យមានចីរភាព ពីព្រោះថានៅក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលនៃការអភិវឌ្ឍន៍ ជាពិសេសការប្រកួតប្រជែងនៅលើទីផ្សារសេរីក្នុងតំបន់ និងការធ្វើសកលភាវូបនីយកម្ម។

ការសិក្សានេះធ្វើឡើងក្នុងគោលបំណង :

- ធានាការធ្វើវិនិយោគក្នុងរយៈពេលយូរអង្វែង
- យល់ដឹងពីធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់
- វាយតំលៃល័ក្ខខ័ណ្ឌសេដ្ឋកិច្ច-សង្គម ដែលមានស្រាប់នៅជុំវិញទីតាំងគំរោង



Draft

- កំណត់សក្តានុពល និងរកមូលហេតុនៃការប៉ះពាល់ទៅលើធនធានធម្មជាតិ និងសង្គម ដោយសារសកម្មភាពនៃការធ្វើវិនិយោគរបស់ក្រុមហ៊ុន
- កំណត់វិធានការរាល់ហេតុប៉ះពាល់អវិជ្ជមានដែលកើតមានឡើងពីសកម្មភាពគំរោងឱ្យដល់កំរិតអប្បបរមា
- ដកស្រង់អនុសាសន៍ល្អៗពីស្ថាប័នពាក់ព័ន្ធលើវិធានការការពាររយៈពេលខ្លី-វែង និងលទ្ធផល ឬឥទ្ធិពលមិនល្អរបស់គំរោងដែលបានស្នើសុំ
- ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាព។

ក្នុងគោលបំណងបន្ទាប់មកទៀត គឺលើការអនុវត្តច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល និងគោរពតាមការណែនាំរបស់មន្ត្រីមានសមត្ថកិច្ច អ្នកដែលពាក់ព័ន្ធនានា និងចង់បង្ហាញពីការចូលរួមរបស់សាធារណៈជនដូចជា : សហគមន៍ព្រៃឈើ សហគមន៍អ្នកប្រើប្រាស់ទឹក និងសហគមន៍ផ្សេងៗទៀត។ល។

## ១.៣ វិធីសាស្ត្រនៃការសិក្សា

### ១.៣.១ ការរៀបចំគំរោងនៃការសិក្សា

គំរោងនៃការសិក្សាស្រាវជ្រាវមានសារៈសំខាន់ណាស់ក្នុងការរៀបចំនូវរបាយការណ៍នេះ ពីព្រោះវាជាផ្លូវឆ្ពោះទៅរកដំណោះស្រាយនៃចំណោទបញ្ហា។ ការសិក្សាតាមដំណាក់កាលមួយចំនួន ដែលត្រូវបានរៀបចំសំរាប់ដំណើរការ និងអភិវឌ្ឍគំរោងនៃការសិក្សាស្រាវជ្រាវនេះ។

ដំណាក់កាលទាំងនេះរួមមាន :

១- ការសិក្សាពីការបង្កើតគំរោង ដោយចាប់ផ្តើមចេញពីការកំណត់បទដ្ឋានច្បាប់ និងបច្ចេកទេស

២- ការសិក្សាពីគោលបំណងដែលឆ្ពោះទៅរកកំណត់នូវប្រភព និងប្រភេទព័ត៌មាន រួមផ្សំវិធីសាស្ត្រក្នុងការសិក្សា

៣- ការរៀបចំកំរងសំណួរដែលទាក់ទងនឹងគំរោង

៤- ការរៀបចំក្រុមការងារចុះសិក្សាស្រាវជ្រាវ

៥- ការចុះប្រមូលឯកសារ និងទិន្នន័យដែលទាក់ទងនឹងគំរោង

៦- ការវិភាគទិន្នន័យ

៧- របកគំហើញនៃការសិក្សា

៨- ការសន្និដ្ឋាន និងអនុសាសន៍



Draft

### ១.៣.២ ការរៀបចំក្រុមចុះសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូង លើគំរោងវិនិយោគដីសម្បទានសេដ្ឋកិច្ចនេះ ត្រូវបានធ្វើឡើងដោយក្រុមសិក្សារបស់ក្រុមហ៊ុន **ហ្គ្រីន អ៊ីនវ៉ាយរ៉ូនមិន គ្រុប (Green Environment Group Co., Ltd.)** ដែលជាក្រុមសិក្សាមានសមាសភាពមកពីជំនាញចំរុះ ហើយក្រុមការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូង មានចំនួន ៧ នាក់ ដូចមានរាយនាមដូចខាងក្រោម ៖

១. លោក ខាំ លីហួត ជំនាញសិក្សាធនធានសេដ្ឋកិច្ចសង្គម និងគ្រប់គ្រងព័ត៌មាន ( ប្រធានក្រុម)
២. លោក អ៊ួច ឈួង ជំនាញធនធានជីវសាស្ត្រ ( អនុប្រធានក្រុម)
៣. លោក ជ្រូក សេងហាក់ ជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
៤. លោក ម៉ៅ រតនា ជំនាញសិក្សាធនធានបរិស្ថាន
៥. លោក សុខ បញ្ញាវុធ ជំនាញសិក្សាធនធានបរិស្ថាន
៦. លោក សិទ្ធ សីហា ជំនាញសិក្សាធនធានសេដ្ឋកិច្ចសង្គម
៧. លោក មាឃ សាគ្គារ ជំនួយការទីវាល

### ១.៣.៣ ការកំណត់ទីតាំងនៃការសិក្សា

ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ នឹងផ្តោតទៅលើទីតាំងដែលក្រុមហ៊ុនវិនិយោគស្នើសុំពីក្រសួងបរិស្ថាន លើទំហំផ្ទៃដី ៤.២៧៣ ហិកតា ស្ថិតនៅឃុំប៊ូស្រា ស្រុកពេជ្រាដា និងឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ។ ហេតុនេះ ទីតាំងដែលពាក់ព័ន្ធក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ រួមមាន៖

**តារាង ១.១ : ទីតាំងនៃការសិក្សា**

| ខេត្ត | ស្រុក | ឃុំ | ភូមិ |
|---|---|---|---|
| ខេត្តមណ្ឌលគិរី | ស្រុកពេជ្រាដា | ឃុំប៊ូស្រា | ភូមិពូទឹត |
| | | | ភូមិពូរាំង |
| | | | ភូមិប៊ូស្រា |
| | | | ភូមិពូចារ |
| | | | ភូមិឡាំមេះ |
| | | | ភូមិពូលុ |
| | ស្រុកអូររាំង | ឃុំដាក់ដាំ | |

*ប្រភព: Green Environment Group Co., Ltd, ២០០៩*

## ១.៣.៤ ប្រភព និងវិធីសាស្ត្រនៃការប្រមូល និងការវិភាគ-វាយតំលៃ

### ក. ប្រភព និងការប្រមូលទិន្នន័យ

ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងលើគំរោងនេះ ធ្វើឡើងដោយផ្អែកលើប្រភពព័ត៌មាន ២ ប្រភេទ : ព័ត៌មានបន្ទាប់បន្សំ និងព័ត៌មានបឋម ។

### ក.១ ព័ត៌មានបន្ទាប់បន្សំ

ប្រភពព័ត៌មានបន្ទាប់បន្សំ ត្រូវបានប្រមូលពីតាមស្ថាប័នពាក់ព័ន្ធនានា ដែលរួមមានឯកសារ :

- **ព្រះរាជក្រឹត្យ និងច្បាប់:** (១) ច្បាប់ស្តីអំពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (២) ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (៣) ច្បាប់ភូមិបាល (៤) ច្បាប់ស្តីពីព្រៃឈើ (៤) ច្បាប់ស្តីពីការងារ (៥) ច្បាប់ជលផល (៦) ច្បាប់គ្រប់គ្រងធនធានទឹក (៧) ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (៨) ច្បាប់ស្តីពីជីវសុវត្ថិភាព
- **អនុក្រឹត្យ:** (១) អនុក្រឹត្យស្តីអំពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (២) អនុក្រឹត្យស្តីអំពីការត្រួតពិនិត្យការបំពុលទឹក (៣) អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង និង (៤) អនុក្រឹត្យស្តិពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង (៤) អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច (៥) អនុក្រឹត្យស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារ ធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- ព័ត៌មានស្តីអំពីធនធានរូបសាស្ត្រ និងជីវសាស្ត្រនៅក្នុងតំបន់ ដែលបកស្រាយអំពីប្រព័ន្ធផ្លូវទឹក អាកាសធាតុ និងប្រភេទដីជាដើមនោះ រួមមាន: (១) ឯកសារស្តីពីស្ថានភាពធនធានព្រៃឈើ ផ្អែកលើផែនទីគម្របព្រៃឈើឆ្នាំ២០០២ របស់រដ្ឋបាលព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា (២) ឯកសារស្តីពីប្រភេទដីរបស់លោក Charles D. Crocker ឆ្នាំ១៩៦២ (៣) ផែនទីភូមិសាស្ត្រ (Topography Map) របស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ឆ្នាំ២០០២ ក្នុងមាត្រដ្ឋាន ១:៥០.០០០ និង ១:១០០.០០០ (៤) ផែនទីស្តីពីភូគព្ភសាស្ត្ររបស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ឆ្នាំ២០០២ និង (៥) ទិន្ន-ន័យអាកាស-ធាតុខេត្តមណ្ឌលគីរីបានពីនាយកដ្ឋានឧតុនិយម ឆ្នាំ ២០០៨ ។
- ព័ត៌មានស្តីអំពីធនធានសង្គម និងសេដ្ឋកិច្ច ដែលមានស្រាប់នៅក្នុងសៀវភៅទិន្នន័យភូមិ និងទិន្នន័យឃុំសំរាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ ដោយរួមមាន ស្ថិតិចំនួនប្រជាជន មុខរបរ សិក្សាធិការ សេវាកម្មមូលដ្ឋាន ការប្រើប្រាស់ទឹក ការប្រើប្រាស់ដី ប្រពៃណី វប្បធម៌ និងប្រព័ន្ធគមនាគមន៍ជាដើម ។
- ឯកសារបានពីក្រុមហ៊ុនអនុវត្តគំរោងរួមមាន : សៀវភៅផែនការមេរបស់ក្រុមហ៊ុន អាជ្ញាប័ណ្ណនានាចេញពីស្ថាប័នពាក់ព័ន្ធ សៀវភៅលក្ខន្តិកៈរបស់ក្រុមហ៊ុន និងសៀវភៅកិច្ចសន្យារបស់ក្រុមហ៊ុនជាមួយនឹងក្រសួងបរិស្ថាន ។

Draft

### ក.២ ព័ត៌មានបឋម

ប្រភពព័ត៌មានបឋម ត្រូវបានចុះប្រមូលដោយផ្ទាល់ ដោយក្រុមសិក្សាស្រាវជ្រាវ ដែលក្នុងនោះរួមមាន :

- ព័ត៌មានស្តីពីស្ថានភាពធនធានរូបសាស្ត្រ និងជីវសាស្ត្រ រួមមាន: (១) ការពិនិត្យអំពីគុណភាពទឹក តាមរយៈការចុះយកសំណាកទឹកមកធ្វើការវិភាគនៅក្នុងទីពិសោធន៍របស់ក្រសួងបរិស្ថាន (២) ការចុះអង្កេតព្រៃឈើ ដើម្បីកំណត់នូវប្រភេទ ទំហំ និងចំនួនដើមឈើ (៣) ការសាកសួរប្រជាជនក្នុងតំបន់អំពីប្រភេទសត្វនៅក្នុងតំបន់ និងការថតរូបយកសំណាកនៃសត្វ (អាចម៍, ស្នាមជើង, ស្នាមលើដើមឈើ និងរបស់សំណាកផ្សេងទៀត) ដោយប្រើនូវវិធីសាស្ត្រ ដើរកាត់ទទឹង (Transit Walk) និងបញ្ជីឈ្មោះសត្វដែលមាននៅក្នុងតំបន់។
- ព័ត៌មានស្តីពីស្ថានភាពធនធានសេដ្ឋកិច្ច-សង្គម ដោយផ្តោតសំខាន់អំពី :
  - ប្រាក់ចំណូលរបស់គ្រួសារនៅក្នុងតំបន់មួយៗ ដោយប្រើប្រាស់នូវកំរងសំណួរ
  - (១) តំបន់ការពារនានា និងដីពាក់ព័ន្ធរវាងប្រជាជន និងគំរោងអភិវឌ្ឍន៍ (២) មតិយោបល់របស់ប្រជាជនចំពោះគំរោងអភិវឌ្ឍន៍ និងសំណូមពរ ដោយក្នុងនោះយើងនឹងប្រើប្រាស់នូវវិធីសាស្ត្រវាយតំលៃជនបទដោយរហ័ស (RRA) ដោយរួមមានវិធីសាស្ត្រ ក-ការពិភាក្សាជាក្រុម ខ-ការគូរផែនទីក្នុងតំបន់ និង គ-ការរៀបចំប្រតិទិនរដូវកាល
  - មតិយោបល់របស់ស្ថាប័ន និងមន្ទីរជំនាញពាក់ព័ន្ធមាន (១) មន្ទីរបរិស្ថាន (២) មន្ទីរកសិកម្ម (៣) មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (៤) ខណ្ឌរដ្ឋបាលព្រៃឈើ (៥) សង្កាត់រដ្ឋបាលព្រៃឈើ ដើម្បីស្វែងយល់អំពីការប៉ះពាល់របស់គំរោង និងវិធីសាស្ត្រដោះស្រាយចំពោះហេតុប៉ះពាល់ទាំងអស់នោះដោយប្រើប្រាស់នូវបញ្ជីសំណួរ និងផែនទីបង្ហាញទីតាំង
  - មតិយោបល់របស់អាជ្ញាធរខេត្ត ស្រុក ឃុំ និងភូមិ ដោយប្រើប្រាស់នូវបញ្ជីសំណួរ និងផែនទីបង្ហាញទីតាំង។ ក្នុងនោះរួមមាន: (១) អាជ្ញាធរខេត្តមណ្ឌលគីរី (២) អាជ្ញាធរស្រុកពេជ្រាដា និងស្រុកអូររាំង (៣) អាជ្ញាធរឃុំប៊ូស្រា និងឃុំដាក់ដាំ (៤) អាជ្ញាធរភូមិពូទីត ភូមិពូរាំង ភូមិប៊ូស្រា ភូមិពូចារ ភូមិឡាំមេះ និងភូមិពូលុ។
  - មតិយោបល់ប្រជាជនភូមិពូទីត, ភូមិពូរាំង, ភូមិប៊ូស្រា, ភូមិពូចារ, ភូមិឡាំមេះ និងភូមិពូលុ។

Draft

តារាង ១.២ : ការប្រមូលព័ត៌មានសំខាន់ៗ សំរាប់ការសិក្សា

| គោលបំណង | តំរូវការព័ត៌មាន | | ប្រភព | ប្រភេទទិន្នន័យ |
|---|---|---|---|---|
| ស្វែងយល់ពីធនធានបរិស្ថាន ដែល | ឋានលេខា | សណ្ឋានដី (រយៈកម្ពស់, កំរិតជំរាល, ទិដ្ឋភាពទី ជំរាល) | - JICA datasheet 2002 | ទិន្នន័យបន្ទាប់បន្សំ |

| | | | | |
|---|---|---|---|---|
| មានស្រាប់នៅក្នុងតំបន់ | | ប្រភេទដី | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០២<br>- Charles D. Crocker 1962 | |
| | ***ភូគព្ភសាស្ត្រ*** | | - JICA datasheet 2002 | ទិន្នន័យបន្ទាប់បន្សំ |
| | ***អាកាសធាតុ*** | សីតុណ្ហភាពខេត្តមណ្ឌលគីរី កំរិតទឹកភ្លៀងខេត្តមណ្ឌលគីរី | - នាយដ្ឋានឧតុនិយម ២០០៨ | ទិន្នន័យបន្ទាប់បន្សំ |
| | | សំណើមបរិយាកាស កំដៅថ្ងៃ | - សៀវភៅផែនការមេរបស់គំរោង | |
| | ***ជលសាស្ត្រ*** | ស្ថានភាពផ្លូវទឹកលើដី | - ចុះអង្កេតផ្ទាល់នៅតំបន់សិក្សា<br>- ការសិក្សាលើផែនទី Topo-map (1:100.000) | ទិន្នន័យបឋម<br>ទិន្នន័យបន្ទាប់បន្សំ |
| | | ការវិភាគកំរិតលំហូរទឹកលើផ្ទៃដី | - JICA Elevation Dataset 2002<br>- ចុះអង្កេតផ្ទាល់នៅតំបន់សិក្សា | ទិន្នន័យបន្ទាប់បន្សំ<br>ទិន្នន័យបឋម |
| | | គុណភាពទឹកលើដី | - យកសំណាកទឹកនៅតំបន់សិក្សាចូលមន្ទីរពិសោធន៏របស់ក្រសួងបរិស្ថាន | ទិន្នន័យបឋម |
| | ***សំលេង*** | | - ចុះសិក្សាដោយផ្ទាល់ក្នុងតំបន់ | ទិន្នន័យបឋម |
| | ***ការគ្រប់គ្រងសំណល់រឹង និងរាវ*** | | - ចុះអង្កេតផ្ទាល់ក្នុងតំបន់សិក្សា<br>- សម្ភាសន៏ប្រជាជន អាជ្ញាធរមូល ដ្ឋាន ពីរបៀបនៃការគ្រប់គ្រងសំណល់ក្នុងតំបន់។ | ទិន្នន័យបឋម |
| | ***ធនធានព្រៃឈើ និងសត្វព្រៃ*** | | - ចុះអង្កេតផ្ទាល់នៅតំបន់សិក្សា<br>- សាកសួរប្រជាជនក្នុងតំបន់ពី | ទិន្នន័យបឋម |

Draft

| | | | |
|---|---|---|---|
| | | ស្ថានភាពធនធានព្រៃឈើ និងសត្វព្រៃ<br>- ធ្វើការចុះអង្កេតព្រៃឈើ និងសត្វ ព្រៃដោយក្រុមសិក្សា | |
| | ***ធនធានសេដ្ឋកិច្ច-សង្គម*** | - ចុះអង្កេតផ្ទាល់ក្នុងតំបន់សិក្សា<br>- សម្ភាសន៍ប្រជាជនក្នុងភូមិពាក់ព័ន្ធ ឬភូមិដែលទទួលរង ការប៉ះ-ពាល់<br>- ប្រមូលព័ត៌មានដែលពាក់ព័ន្ធរួមមានស្ថិតិប្រជាជន | ទិន្នន័យបឋម<br>ទិន្នន័យបន្ទាប់បន្សំ |
| ធ្វើការពិនិត្យលើកដំបូងទៅលើការប៉ះពាល់ដោយផ្ទាល់ ឬប្រយោលចំពោះតំបន់គំរោង អភិវឌ្ឍន៍ និងតំបន់ជុំវិញគំរោង | ***ហេតុប៉ះពាល់វិជ្ជមានពីគំរោងចំពោះសង្គម*** | - សម្ភាសន៍ប្រជាជនពីការប៉ះពាល់ដែលអាចកើតមានពីគំរោង<br>- ចុះអង្កេតផ្ទាល់នៅក្នុងទីតាំងដែល រងការប៉ះពាល់<br>- ធ្វើក្រុមពិភាក្សាជាមួយប្រជា-ជន និងអាជ្ញាធរមូលដ្ឋាន ដើម្បីយកមតិយោបល់ និង សំណូមពររបស់ពួកគាត់ ទៅលើគំរោង | ទិន្នន័យបឋម |

*ប្រភព: Green Environment Group Co., Ltd, ២០០៩*

## ខ. ការវិភាគ-វាយតំលៃ

ក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងលើគំរោងវិនិយោគនេះ ក្រុមសិក្សានឹងប្រើប្រាស់នូវវិធីសាស្ត្រ វិភាគបែបគុណភាព និងបរិមាណ។ ចំពោះការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន នឹងប្រើប្រាស់នូវវិធីសាស្ត្រវាយតំលៃតាម (១)បញ្ជីផ្ទៀងផ្ទាត់ (Checklist) ដើម្បីកំណត់នូវទំហំនៃហេតុប៉ះពាល់អវិជ្ជមានទាំងឡាយ និង (២)វិធីសាស្ត្រផ្អែកតាមផែនទី ដោយប្រើប្រាស់កម្មវិធី ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដើម្បីបង្ហាញនូវ តំបន់នានា ដែលនឹងមានការផ្លាស់ប្តូរនៅពេលមានវត្តមាននៃគំរោង ដែលនឹងបង្កនូវហេតុប៉ះពាល់អវិជ្ជមាន ចំពោះធនធានបរិស្ថាន និងសង្គម។

## ១.៤ ដែនកំណត់នៃការសិក្សា

គំរោងវិនិយោគសំរាប់ការបង្កើតកសិដ្ឋានដាំដំណាំកសិ-ឧស្សាហកម្ម (ដើមកៅស៊ូ)របស់ក្រុមហ៊ុន ស្ថិតនៅលើផ្ទៃដីសម្បទានសេដ្ឋកិច្ចទំហំ **៤.២៧៣ ហិកតា**។ ហេតុនេះក្នុងការចុះសិក្សា ពិនិត្យមើលទីតាំងគំរោង អាចត្រូវបានធ្វើឡើងតែក្នុងទំហំតូច ជាពិសេសតែលើតំបន់សំខាន់ៗដូចជា ទីតាំងសាងសង់ ស្នាក់ការ ផ្ទះស្នាក់នៅរបស់បុគ្គលិក-កម្មករគំរោង ទីតាំងថ្នាល និងទីតាំងបំរុង នឹងដាំដុះតែប៉ុណ្ណោះ។

ចំពោះការចុះសិក្សាអំពីធនធានរូបសាស្ត្រ និងជីវសាស្ត្រ មួយផ្នែកធំនៃការសិក្សាគឺផ្អែកលើផែនទីភូមិសាស្ត្រ ដើម្បីកំណត់នូវប្រព័ន្ធផ្លូវទឹកនៅក្នុងតំបន់គំរោង ព្រមទាំងប្រវែងដែលស្ថិតនៅក្នុងតំបន់គំរោង។ ចំនែកការចុះសិក្សាអង្កេតព្រៃឈើ ក្រុមសិក្សានឹងធ្វើឡើងក្នុងចំនួន **១២ គំរូ** ប៉ុណ្ណោះ ក្នុងតំបន់ដែលនឹងមានការឈូសឆាយសំរាប់ការដាំដុះ ដែលជាប្រភេទព្រៃល្បោះ ក្នុងទំហំគំរូ : ៥០ម x ៥០ម។ ចំនែកព្រៃតំបន់រក្សាទុកគឺមិនត្រូវបានធ្វើការសិក្សាទេ ព្រោះគំរោងមិនមានសកម្មភាពអ្វី លើតំបន់នោះទេ។

ចំនែកការសិក្សាអំពីធនធានសេដ្ឋកិច្ច-សង្គម ក្រុមសិក្សានឹងធ្វើឡើងតែជាមួយអាជ្ញាធរថ្នាក់ខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធរបស់ខេត្តមណ្ឌលគីរី និងទីតាំងដែលគំរោងស្ថិតនៅតែប៉ុណ្ណោះ។

Draft

រូបភាព ១.១ : វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ




Draft

*ប្រភព: Green Environment Group Co., Ltd, ២០០៩*